# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 9 – In the classroom
## មេរៀនទី៩ ៖ នៅក្នុងថ្នាក់រៀន

**STUDY NOTES**
ឯកសារជំនួយមេរៀន

<u>តួអង្គ</u>

Angel:
អែនជល ៖ ជានិស្សិតបរទេស ហើយមកប្រទេសអូស្ត្រាលីជាលើកទី១។

Katie:
ខេតធី ៖ ជានិស្សិតបរទេស ហើយមកប្រទេសអូស្ត្រាលីជាលើកទី១។

Rocky:
រ៉ុកឃី ៖ ជានិស្សិតបរទេស ហើយមកប្រទេសអូស្ត្រាលីជាលើកទី១។

Marion
មារៀន ៖ ជាគ្រូបង្រៀនរបស់ពួកគេ។

<u>សាច់រឿង</u>

អែនជល រ៉ុកឃី និងខេតធី មានវត្តមាននៅក្នុងបន្ទប់រៀននាថ្ងៃដំបូង។ នៅម៉ោងសម្រាកខេតធី បានប្រាប់មារៀនថា ថ្នាក់រៀនរបស់នាងមានកម្រិតខ្ពស់ពេកសម្រាប់នាង។

ABC Radio Australia

**<u>ព័ត៌មាន-កាលវិភាគសាលា ELICOS ទូទៅប្រចាំសប្តាហ៍</u>**

សូមចាំថា នៅក្នុងឧទាហរណ៍នេះ ថ្នាក់រៀនចាប់ផ្តើមនៅម៉ោង ១០.៣០នាទីព្រឹក។ ថ្នាក់រៀនអាចចាប់ផ្តើមនៅម៉ោងប៉ុន្មានក៏បានដែរ ដោយចាប់ពីម៉ោង ៨ព្រឹក តទៅ ហើយជាធម្មតានឹងត្រូវបញ្ចប់នៅរយៈពេល៦ម៉ោងបន្ទាប់។

កាលវិភាគដែលមានបង្ហាញអំពីលេខបន្ទប់នេះ នឹងប្រាប់លោកអ្នកអំពីពេលវេលាដែលលោកអ្នកត្រូវរៀនក្នុងបន្ទប់រៀន ជាមួយនឹងគ្រូរបស់លោកអ្នក។ គ្រូបង្រៀនរបស់លោកអ្នក ក៏ជាអ្នកត្រួតពិនិត្យការចំណាយពេលរបស់លោកអ្នកនៅក្នុងបន្ទប់កុំព្យូទ័រផងដែរ។

| | Monday | Tuesday | Wednesday | Thursday | Friday |
|---|---|---|---|---|---|
| 8.30 – 9.30 | | | | | |
| 9.30 –10.30 | | | | | |
| 10.30 – 11.30 | Computer | Room 501 | Room 501 | Computer | Room 104 |
| 11.30 – 12.30 | Computer | Room 501 | Room 501 | Computer | Room 104 |
| 12.30 – 1.30 | Independent | Independent | Independent | Independent | Independent |


© RadioAustralia/AMES 2008

| | | | | | |
|---|---|---|---|---|---|
| | Study (Library) | Study (Library) | Study (Library) | Study (Library) | Study (Library) |
| 1.30 – 2.30 | Break | Break | Break | Break | Break |
| 2.30 – 3.30 | Room 104 | Room 104 | Room 104 | Room 104 | Room 104 |
| 3.30 – 4.30 | Room 104 | Room 104 | Room 104 | Room 104 | Room 104 |
| 4.30 – 5.30 | | | | | |

## ភាសា – សំនួនវោហារ និងឃ្លាដែលមានន័យមិនធម្មតា

| | |
|---|---|
| Australian Justice System | ជាប្រព័ន្ធច្បាប់ និងតុលាការក្នុងប្រទេសអូស្ត្រាលី។ |
| Courts | ជាអគារសាធារណៈសម្រាប់កាត់ក្តី។ |
| Needs analysis | ជាធម្មតា គ្រូធ្វើការស្ទង់អង្កេតដើម្បីវិភាគតម្រូវការសិស្សរបស់ខ្លួន។ ការអង្កេតនេះជាឱកាសរបស់លោកអ្នកសម្រាប់ប្រាប់គ្រូលោកអ្នកនូវអ្វីដែលលោកអ្នកចង់រៀនជាងគេ។ |
| Independent Learning Plan | ជាក្រដាសបង្ហាញអំពីស្វ័យសិក្សា ដែលលោកអ្នករៀនរាល់ថ្ងៃ។ គ្រូរបស់លោកអ្នកនឹងអាន រួចដាក់ពិន្ទុខ្លឹមសារនៃផែនកាស្វ័យសិក្សា (I.L.P) បន្ទាប់មក ពិន្ទុនោះក៏នឹងត្រូវដាក់បញ្ចូលទៅក្នុងពិន្ទុសម្រាប់ការវាយតម្លៃសរុបរបស់លោកអ្នកផងដែរ។ |
| To goof off | ជៀសវាងមិនធ្វើការងារ ឬសិក្សា។ |
| To transfer | ការផ្លាស់ប្តូរពីស្ថានភាពមួយទៅស្ថានភាពមួយទៀត។ ក្នុងករណីនេះ គឺផ្លាស់ប្តូរពីថ្នាក់ភាសាអង់គ្លេសមួយ ទៅថ្នាក់ភាសាអង់គ្លេសមួយទៀត។ |


© RadioAustralia/AMES 2008

# EXERCISES
# លំហាត់

## ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| analysis | assignment | beach |
| bored | break | crime |
| environment | essay | excursion |
| formal | homework | justice |
| mountain | presentation | punishment |
| system | task | trip |

## ២. ការហាត់រៀនភាសា៖ លំហាត់គំរូ- ការធ្វើតេស្តវាស់ស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវឆ្លងកាត់ការធ្វើតេស្តវាស់ស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមចាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best completes each sentence.
ចូរជ្រើសពាក្យដែលស័ក្តិសមបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះពាក្យនៃឃ្លាក្នុងប្រអប់ខាងក្រោម។
សូមគូសខ្វែងក្នុងប្រអប់មួយសម្រាប់លេខនីមួយៗ។ ឧទាហរណ៍ ☒

1. Excuse me, could you _________ me where the computer room is please?

   ☐ talk ☐ speak ☐ tell ☐ say

2. How many hours will we spend _________ independent study?

   ☐ by ☐ an ☐ on ☐ of

3. We get an hour ____________ lunch at 12.30.

   ☐ the ☐ in ☐ to ☐ for

4. We're expected to do __________ least an hour of homework per day.

   ☐ at ☐ about ☐ as ☐ the


© RadioAustralia/AMES 2008

5. Can I talk to you ___________ something please?

☐ for ☐ around ☐ about ☐ on

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

សូរសំឡេង / ʃ/ /ʧ/ /ʤ/ ៖សូមហាត់និយាយពាក្យដែលត្រូវពត់អណ្តាត ដោយបញ្ចេញសំឡេងឲ្យបានឮៗ ៖

**"She's in a cheap jeep, chasing sheep."**

## ៤. អាសយដ្ឋានអ៊ីនធើរណិតមានប្រយោជន៍

| | |
|---|---|
| **ព័ត៌មាន ៖** សម្រាប់ការបញ្ចេញសំឡេង | http://www.soundsofenglish.org/pronunciation/chdz.html |

ចម្លើយលំហាត់ទី 2: 1) tell 2) on 3) for 4) at 5) about


© RadioAustralia/AMES 2008